ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សេចក្តីប្រកាសព័ត៌មាន
# កិច្ចប្រជុំត្រៀមវាយតម្លៃអញ្ញមញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជានិងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅសណ្ឋាគារសានវេ

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦

នាព្រឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ នៅសណ្ឋាគារសានវេ មានប្រារព្ធពិធីបើកកិច្ចប្រជុំត្រៀមវាយតម្លៃអញ្ញមញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាលើកទីពីរ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

កិច្ចប្រជុំនេះត្រូវបានរៀបចំដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សហការជាមួយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់ (APG) ដែលមានរយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ក្នុងគោលបំណងពិភាក្សាអំពីដំណើរការនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅប្រទេសកម្ពុជា ។ កិច្ចប្រជុំនេះមានការចូលរួមពីតំណាងក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ មន្ត្រីអនុវត្តច្បាប់ និងតំណាងវិស័យឯកជន សរុបចំនួន ១០០ រូប ។

ថ្លែងនៅក្នុងពិធីបើកកិច្ចប្រជុំនេះ ឯកឧត្តម **ជា ចាន់តូ** បានជម្រាបជូនអង្គប្រជុំអំពីកិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលការងាររបស់រដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការរៀបចំឲ្យមានយុទ្ធសាស្ត្រជាតិ ការពង្រឹងក្របខ័ណ្ឌគតិយុត្តិ និងយន្តការអនុវត្តច្បាប់និងការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទាំងក្នុងស្រុកនិងអន្តរជាតិលើការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រហូតមានការទទួលស្គាល់ពីក្រុមការងារហិរញ្ញវត្ថុ (FATF) និងបានធ្វើឲ្យប្រទេសកម្ពុជាយើងក្លាយជាសមាជិករបស់ក្រុម Egmont ថែមទៀត ។ ជាមួយគ្នានេះ ឯកឧត្តមក៏បានបញ្ជាក់បន្ថែមអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលបន្តការយកចិត្តទុកដាក់និងកិច្ចខិតខំប្រឹងប្រែង លើការងារកិច្ចសហការជាមួយសហគមន៍អន្តរជាតិក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជាពិសេសជាមួយ APG ។

បន្ទាប់មក ឯកឧត្តម **ជា ចាន់តូ** ក៏បានស្នើឲ្យសមាជិកអង្គប្រជុំបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រេចតាមយុទ្ធសាស្ត្រ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់សកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងផ្តល់កិច្ចសហការល្អដល់ក្រុមការងាររបស់ APG ដើម្បីឲ្យកិច្ចប្រជុំប្រព្រឹត្តទៅដោយជោគជ័យ ។